ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ុំង គិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ីវ ប៉ូលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុកនួន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ គិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មាននួ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិសុត្ត
២០-មេធាវី លឹម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួវ
២៣-មេធាវី វ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ: ០៦៤ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមេសា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យដាក់ក្នុងស្ថានភាពមេធាវីសុំមិនប្រកបវិជ្ជាជីវៈ

## ប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- យោងតាមសំណើសាមីខ្លួន ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦។

## សម្រេច

**ប្រការ ១.-** អនុញ្ញាតឱ្យលោកមេធាវី **ចាន់ វណ្ណៈ** អត្តលេខ **៣៦២** ស្ថិតក្នុងស្ថានភាពមេធាវីសុំមិនប្រកបវិជ្ជាជីវៈរយៈពេល ០២(ពីរ)ឆ្នាំ **គិតចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨** តាមសំណើសាមីខ្លួន។

អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៩ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៨៦៤ ០៧៨
ទូរសារ: (៨៥៥-២៣) ៨៦៤ ០៧៦, E-mail: info@bakc.org.kh, website: www.bakc.org.kh

**ប្រការ ២.-** រយៈពេលស្ថិតក្នុងស្ថានភាពសុំមិនប្រកបវិជ្ជាជីវៈមេធាវីនេះ លោកមេធាវី **ចាន់ វណ្ណៈ** ពុំអាចប្រកបវិជ្ជាជីវៈជាមេធាវីបានទេ ប៉ុន្តែអាចប្រើប្រាស់ឋានៈជាមេធាវីបាន ហើយត្រូវជាប់កាតព្វកិច្ចទាំងឡាយដែលទាក់ទងនឹងវិជ្ជាជីវៈមេធាវី និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈមេធាវី ។

**ប្រការ ៣.-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ៕

**មេធាវី. ប៊ុន_ហុន**

**ចម្លងជូន:**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

*"ដើម្បីជូនជ្រាប"*

-ដូចប្រការ ៤

-ឯកសារ-កាលប្បវត្តិ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: ៩៤៨
-ម៉ោង: ១១.៣០
-ថ្ងៃ ខែ ឆ្នាំ: ២៥ . ៤ . ១៦
-បញ្ជូន: ...

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំមិនប្រកបវិជ្ជាជីវៈមេធាវី

ខ្ញុំបាទឈ្មោះ **ចាន់ វណ្ណៈ** ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ **៣៦២**។

**សូមគោរពជូន**

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ** : សំណើសុំមិនប្រកបវិជ្ជាជីវៈមេធាវី រយៈពេល ០២ឆ្នាំ។

**យោង** : មាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **លោកប្រធាន** មេត្តាជ្រាបថា: ខ្ញុំបាទមានជម្ងឺត្រូវទៅព្យាបាលនៅបរទេស ដូច្នេះខ្ញុំបាទស្នើសុំមិនប្រកបវិជ្ជាជីវៈមេធាវី រយៈពេល ០២ឆ្នាំ **ដោយគិតចាប់ពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨**។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ និងអនុញ្ញាតតាមសំណើសុំដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ៕

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៦

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី.ចាន់ វណ្ណៈ**

គួរឯកភាពតាមសំណើ

25/04/16

**ប៊ុន ណារីណា**